# សុន្ទរកថា
## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុង
## ពិធីផ្ទេរ និង ប្រគល់តំណែងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២២

ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- **ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល;**
- **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ;**
- **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន;**
- **ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម;**
- **ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ;**
- **ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី;**
- **ឯកឧត្តម, លោកជំទាវ, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ;**
- **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!**

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង និង កិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបាន មកចូលរួមជាអធិបតី ក្នុងនាមជាតំណាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីផ្ទេរ និង ប្រគល់តំណែង **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** ។ ជាបឋម, ខ្ញុំសូមសម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅ ក្នុងឱកាសដែល

រដ្ឋសភាជាតិ នីតិកាលទី ៦ បានបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត តែងតាំង **ឯកឧត្តម ឌិត ទីណា ជារដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** តាមសំណើដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង សូមអបអរសាទរផងដែរចំពោះ **ឯកឧត្តម វេង សាខុន** ដែលរាជរដ្ឋាភិបាលបានតែងតាំងជា **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ។

បន្ទាប់ពីបានស្តាប់ដោយយកចិត្តទុកដាក់ នូវរបាយការណ៍របស់ឯកឧត្តម **វេង សាខុន** អំពីវឌ្ឍនភាពការងាររបស់ក្រសួង ដោយគូសរំលេចអំពីការយកចិត្តទុកដាក់ ក្នុងការជំរុញការអភិវឌ្ឍវិស័យកសិកម្ម, ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះ ឯកឧត្តម **វេង សាខុន**, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ និង មន្រ្តីរាជការទាំងអស់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានខិតខំប្រឹងប្រែងបំពេញតួនាទី, ភារកិច្ច និង បេសកកម្មរបស់ខ្លួន យ៉ាងខ្ជាប់ខ្ជួន ប្រកបដោយស្មារតីទទួលខុសត្រូវ ហើយសម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ នាពេលកន្លងមក ។ ទន្ទឹមនេះ, ខ្ញុំក៏សូមកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់ ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការបន្តជំរុញអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ឱ្យក្លាយជាសសរទ្រូងដ៏រឹងមាំមួយ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ និង ផលប្រយោជន៍របស់ប្រជាកសិករ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និង ភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា**, កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ប្រមាណ ៧% ក្នុងចន្លោះឆ្នាំ ២០១០-២០១៩ ។ ទោះបីជាវិបត្តិនៃជំងឺកូវីដ-១៩ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះដល់ -៣,១% ក្នុងឆ្នាំ ២០២០, ការដាក់ចេញ និង អនុវត្តនូវវិធានការរដ្ឋបាល និង សុខាភិបាល ប្រកបដោយភាពម៉ឺងម៉ាត់ និង ប្រសិទ្ធភាព, គួបផ្សំនឹងការអនុវត្តដោយជោគជ័យ នូវយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស ដែលធ្វើឱ្យកម្ពុជាសម្រេចបានភាពស៊ាំសហគមន៍កម្រិតខ្ពស់ បានអនុញ្ញាតឱ្យកម្ពុជាបើកសកម្មភាពសង្គម-សេដ្ឋកិច្ចលើគ្រប់វិស័យ មុនប្រទេសជាច្រើននៅក្នុងតំបន់ និង លើសកលលោក ចាប់តាំងពីចុងឆ្នាំ ២០២១ មក ។ ទន្ទឹមនេះដែរ, ការដាក់ចេញ និង អនុវត្តនូវ **ក្របខណ្ឌយុទ្ធសាស្រ្ត និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣** បានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជា ងើបឡើងវិញក្នុងអត្រាប្រមាណ ៣% នៅឆ្នាំ

២០២១ និង រំពឹងថាសម្រេចបាន ក្នុងអត្រាកំណើនប្រមាណជាង ៥,០% ក្នុងឆ្នាំ ២០២២ និង ប្រមាណ ៦,០% ក្នុងឆ្នាំ ២០២៣ ខាងមុខ ។

ស្របពេលដែលកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចល្អប្រសើរ, វិស័យកសិកម្មក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា នៅលើទិដ្ឋភាពសំខាន់ៗចំនួន ៤ មានជាអាទិ៍៖ **ទី១.**ការរក្សានិរន្តភាពសន្តិសុខស្បៀង; **ទី២.**ការកាត់បន្ថយភាពក្រីក្រ; **ទី៣.**ការចូលរួមចំណែកក្នុងការលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ; និង **ទី៤.**ការបង្កើតការងារ ។ ក្នុងរយៈពេលជិតមួយទសវត្សរ៍ចុងក្រោយនេះ ដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ជាពិសេស ប្រព័ន្ធធារាសាស្ត្រ, ការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធដល់វិស័យកសិកម្ម ដូចជា ការនាំចូលវត្ថុធាតុដើមកសិកម្ម និង ការចិញ្ចឹមសត្វ និង ការផ្តល់កិច្ចសម្រួលពាណិជ្ជកម្មល្អប្រសើរ សម្រាប់ការនាំចេញផលិតផលកសិកម្ម ជាដើម, វិស័យកសិកម្មកម្ពុជាទទួលបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនផលិតកម្មកសិកម្ម និង ការនាំចេញផលិតផលកសិកម្មគ្រប់ប្រភេទ ។ ជាការពិត, វិស័យកសិកម្មបានរួមចំណែកប្រមាណ ៦០% ក្នុងការកាត់បន្ថយភាពក្រីក្រ ឱ្យធ្លាក់ចុះពីអាត្រា ៥០% ក្នុងឆ្នាំ ២០០៧ មកត្រឹម ២១% ក្នុងឆ្នាំ ២០១១ ។ នៅក្នុងឆ្នាំ ២០២១ កន្លងទៅ, វិស័យកសិកម្មក៏បានរួមចំណែកប្រមាណ ២២,៨% ក្នុង ផ.ស.ស និង បានបង្កើតការងារជូនប្រជាពលរដ្ឋប្រមាណជាង ៣ លាននាក់ផងដែរ ។ ជាមួយគ្នានេះ, ក្នុងពេលវិបត្តិជំងឺកូវីដ-១៩កន្លងមក, វិស័យកសិកម្មក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់ស្បៀងអាហារ, រក្សាលំនឹងជីវភាពប្រជាជន និង ផ្តល់ការងារដល់បងប្អូនជាពលករចំណាកស្រុក និង កម្មករនៅក្នុងវិស័យផ្សេងទៀតនៃសេដ្ឋកិច្ច ដែលទទួលរងនូវផលប៉ះពាល់ខ្លាំងពីវិបត្តិនៃជំងឺកូវីដ-១៩ ។

ក្នុងរយៈពេលមធ្យម និង វែងទៅមុខ, រាជរដ្ឋាភិបាលនៅតែចាត់ទុកកសិកម្ម ជាវិស័យអាទិភាព, ទាំងនៅលើទិដ្ឋភាពសន្តិសុខស្បៀង, ការរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងពេលមានវិបត្តិ, ការបង្កើតការងារ និង ការចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ។ យ៉ាងណាមិញ, ទន្ទឹមនឹងការរីកចម្រើនគួរឱ្យកត់សម្គាល់, វិស័យកសិកម្មកម្ពុជានៅតែមានបញ្ហាប្រឈមជារចនាសម្ព័ន្ធមួយចំនួនដូចជា៖ **ទី១.**កំណើនផលិតភាពកសិកម្មនៅមានកម្រិតទាប ដែលបណ្តាលមកពីកត្តាកង្វះការប្រើប្រាស់ពូជសុទ្ធល្អ; កង្វះការអនុវត្តបច្ចេកទេស និង បច្ចេកវិទ្យាឱ្យបានសមស្រប; ភាពមានកម្រិត និង មិនទាន់ប្រទាក់ក្រឡាគ្រប់ជ្រុងជ្រោយ នៃប្រព័ន្ធស្រោចស្រព បើទោះបីជារដ្ឋាភិបាលបានខិតខំជំរុញការវិនិយោគ ក្នុងទំហំទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ក្តី និង ការធ្លាក់ចុះគុណភាពដីកសិកម្ម ស្របពេលដែលកម្ពុជាស្ថិតក្នុងស្ថានភាពមួយ ដែលពុំអាចមានលទ្ធភាពច្រើន ក្នុងការពង្រីកដីកសិកម្មបន្ថែមទៀត;

ទី២.កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្រោយពេលប្រមូលផល ដូចជា៖ ប្រព័ន្ធដឹកជញ្ជូនត្រជាក់, កន្លែងត្រួតពិនិត្យ និង បញ្ជាក់គុណភាព, កន្លែងប្រមូលផ្តុំ និង ទីផ្សារបោះដុំផលិតផលកសិកម្ម ជាដើម ខណៈដែលប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាព សម្រាប់គាំទ្រដល់ការនាំចេញផលិតផលកសិកម្ម នៅមានភាពទន់ខ្សោយនៅឡើយ និង មិនទាន់អាចឆ្លើយតបបានពេញលេញទៅនឹងលក្ខខណ្ឌតម្រូវ និង ស្តង់ដារបស់ប្រទេសបញ្ជាទិញ; ទី៣.កង្វះការកែច្នៃផលិតផលកសិកម្ម; ទី៤.ការនាំចេញផលិតផលកសិកម្មភាគច្រើនទៅកាន់ប្រទេសជិតខាង នៅមានលក្ខណៈក្រៅផ្លូវការ ដែលជាទូទៅធ្វើឱ្យទទួលរងហានិភ័យនៃការប្រែប្រួលថ្លៃ; និង ទី៥.កង្វះការសម្របសម្រួលស្ថាប័ន និង ការធ្វើសុខដុមនីយកម្មគម្រោង និង កម្មវិធីដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ក្នុងពេលដែលយើងកំពុងតែប្រារព្ធពិធីផ្ទេរតំណែងនេះ, វិស័យកសិកម្មរបស់យើងកំពុងតែទទួលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀងស្ទើរតែទូទាំងប្រទេស ។ ទឹកជំនន់ក្នុងឆ្នាំនេះមានរយៈពេលអូសបន្លាយយូរជាងឆ្នាំកន្លងទៅ ដែលជាហេតុធ្វើឱ្យមានផលប៉ះពាល់ច្រើន ដល់ដំណាំរបស់បងប្អូនប្រជាកសិករ ។ ផ្អែកតាមការវាយតម្លៃបឋមរបស់ក្រុមការងារ, គិតត្រឹមថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០២២, ដំណាំស្រូវដែលទទួលរងផលប៉ះពាល់សរុបមានចំនួន ២០៦ ៧៧៣ ហិកតា, ផ្ទៃដីដំណាំស្រូវដែលបានខូចខាតមានចំនួន ៨៥ ១២៨ ហិកតា និង ផ្ទៃដីដំណាំស្រូវដែលអាចស្តារឡើងវិញមានចំនួន ៤៨ ៤៧២ ហិកតា ។

ជាមួយនឹងការវាយតម្លៃខ្ពស់ចំពោះការបំពេញការងាររបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការចុះពិនិត្យ វាយតម្លៃ និង ផ្ទៀងផ្ទាត់លើការខូចខាតដោយទឹកជំនន់ ដោយបានធ្វើការសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, រដ្ឋបាលថ្នាក់ក្រោមជាតិ និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ខ្ញុំសូមស្នើឱ្យឯកឧត្តមរដ្ឋមន្ត្រី **ឌិត ទីណា**, ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ចាត់ទុកការងារដោះស្រាយផលប៉ះពាល់ពីទឹកជំនន់នេះ ជាការងារអាទិភាពទីមួយ នាពេលចំពោះមុខ និង អនុវត្តឱ្យបានល្អប្រសើ នូវវិធានការដែលទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលខ្ញុំសូមយកឱកាសនេះ ដើម្បីគូសបញ្ជាក់ដូចខាងក្រោម៖

ទី១.បន្តចុះពិនិត្យ និង វាយតម្លៃផលប៉ះពាល់ និង ការខូចខាតជាក់ស្តែង ដោយសារជំនន់ទឹកភ្លៀង លើដំណាំកសិកម្ម, សត្វពាហនៈ និង វារីវប្បកម្ម ជាពិសេស កំណត់ឱ្យច្បាស់លាស់ នូវ

ទីតាំងខូចខាត, ទំហំផ្ទៃដី និង ចំនួនគ្រួសារកសិករដែលរងគ្រោះ ដោយសហការជាមួយក្រសួង-ស្ថាប័ន ជាពិសេស រដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ទី២.**បន្តធ្វើយុទ្ធនាការស្តារឡើងវិញ នូវផ្ទៃដីដាំដុះដែលទទួលរងនូវការខូចខាត ដោយទឹកជំនន់ និង នាំយកពូជស្រូវ, ពូជដំណាំ, ពូជត្រី និង កង្កែប ទៅចែកជូនប្រជាកសិករតាមខេត្តគោលដៅ ដែលរងផលប៉ះពាល់ ដើម្បីឆ្លើយតបទៅនឹងទំហំនៃការខូចខាតដំណាំកសិកម្ម, ផលិតកម្មសត្វ និង វារីវប្បកម្មដែលបានកើតមានឡើងកន្លងមក ។

**ទី៣.**ណែនាំដល់ថ្នាក់ដឹកនាំក្រសួង, អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រាជធានី-ខេត្ត ចូលរួមសហការសម្របសម្រួល ធ្វើប្រតិបត្តិការឆ្លើយតបទៅនឹងគ្រោះធម្មជាតិនេះ និង ពន្លឿនការស្តារឡើងវិញ នូវផលប៉ះពាល់នៅតាមបណ្តាខេត្តគោលដៅរបស់ខ្លួន ។

**ទី៤.**សហការជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ស្នើត្រៀមគ្រាប់ពូជស្រូវ និង ពូជដំណាំរួមផ្សំផ្សេងទៀតឱ្យបានគ្រប់គ្រាន់ និង ចាត់ចែងបញ្ជូនឱ្យទាន់ពេលវេលា ទៅដល់គោលដៅចែកចាយ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេស សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និង ចាត់ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សកម្មចុះជួយគាំទ្រការងារបច្ចេកទេសនៅពេលដាំដុះស្តារឡើងវិញ ។

**ទី៥.**ជំរុញអង្គភាពជំនាញ ឱ្យខិតខំយកចិត្តទុកដាក់ បន្តចុះពិនិត្យតាមដានសុខភាពសត្វ, ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និង ទប់ស្កាត់ចលនាសត្វដោយខុសច្បាប់ នៅតាមបណ្តារាជធានី-ខេត្តជាប់ជាប្រចាំ រួមទាំងបទល្មើសជលផល និង ព្រៃឈើផងដែរ ។ និង

**ទី៦.**ផ្តល់ការសហការជិតស្និតជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការប្រមូលទិន្នន័យអំពីតម្រូវការពូជ, ផ្ទៃដីស្តាឡើងវិញ, អត្តសញ្ញាណជនរងគ្រោះ និង ព័ត៌មានដទៃទៀត ដើម្បីដាក់ចេញនូវវិធានការស្តារ និង ផ្តល់ជំនួយសង្គមផ្សេងៗទៀត ប្រកបដោយប្រសិទ្ធភាព ។

បន្ថែមពីលើការងារអាទិភាពនាពេលចំពោះមុខ ដូចបានគូសបញ្ជាក់ខាងលើ, ក្នុងគោលដៅបន្តជំរុញអភិវឌ្ឍវិស័យកសិកម្ម ក៏ដូចជាទាញយកឱ្យអស់នូវសក្តានុពលដ៏ធំធេងពីវិស័យនេះ, ខ្ញុំសូមធ្វើការគូសរំលេចនូវកិច្ចការជាអាទិភាពសំខាន់ៗមួយចំនួន សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ផ្តោតការយកចិត្តទុកដាក់ ក្នុងរយៈពេលខ្លី, មធ្យម និង វែងខាងមុខ ដូចខាងក្រោម ៖

**ទី១.**អនុវត្តការងារក្នុងស្មារតីបុរេសកម្ម ដោយតាមដាន និង វាយតម្លៃជាប្រចាំ អំពីស្ថានភាពទូទៅនៃវិស័យកសិកម្ម និង ដោះស្រាយបញ្ហាប្រឈមនានា ឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ ។

**ទី២.**ជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវ **គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ ២០២២-២០៣០; ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុង**

**ការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣** និង ពន្លឿនការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ ២០៣០ ។

**ទី៣.**ធ្វើឱ្យប្រសើរឡើង នូវផលិតភាពកសិកម្ម តាមរយៈការពង្រឹងការគ្រប់គ្រងគុណភាពដី, ការផ្តល់សេវាបច្ចេកទេសកសិកម្មឱ្យសមស្របតាមតម្រូវការរបស់ប្រជាជន, ការប្រើប្រាស់បច្ចេកវិទ្យា, ការជ្រើសរើសពូជដំណាំ, ការកាត់បន្ថយថ្លៃដើមផលិតកម្ម, ការប្រើប្រាស់ជាតុចូលសមស្រប និង ការអនុវត្តកសិកម្មល្អ, ព្រមទាំងការពង្រឹង និង ការកែលម្អសមត្ថភាពកសិដ្ឋាន, ស្ថានីយពិសោធន៍ និង មជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ឱ្យក្លាយជា **មជ្ឈមណ្ឌលឧត្តមភាពកសិកម្ម** សម្រាប់ផ្សព្វផ្សាយទៅតាមឯកទេសសមស្រប ។

**ទី៤.**ជំរុញការដាំដុះបន្លែ តាមរយៈការអនុវត្តកសិកម្មល្អ និង ការប្រើប្រាស់ផ្ទះសំណាញ់ ឬផ្ទះកញ្ចក់ ដោយមានការរៀបចំផែនការផលិតកម្ម និង កិច្ចសន្យាកសិកម្មច្បាស់លាស់ ជាមួយទីផ្សារ; ជំរុញវារីវប្បកម្មគ្រប់រូបភាពឲ្យបានខ្លាំងក្លាស្របតាម **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្ម ឆ្នាំ ២០១៦-២០៣០** និង ជំរុញផលិតកម្មសត្វ ដើម្បីធានាបាននូវការផ្គត់ផ្គង់សាច់សត្វ, ត្រី និង បន្លែក្នុងស្រុក សំដៅកាត់បន្ថយការពឹងផ្អែកលើការនាំចូល; និង ជំរុញការនាំចេញ ។

**ទី៥.**បន្តជំរុញផលិតកម្មស្រូវ ជាពិសេស ស្រូវក្រអូប និង ដំណាំកសិ-ឧស្សាហកម្ម ដែលមានសក្តានុពល ដូចជា៖ ដំឡូងមី, កៅស៊ូ, ស្វាយចន្ទី, ដូង, ស្វាយ, ពោតក្រហម និង មៀនប៉ៃលិន ជាដើម តាមរយៈការបង្កើនការផ្គត់ផ្គង់ និង ការប្រើប្រាស់ពូជដែលសុទ្ធ និង មានថ្លៃសមរម្យ, ការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ជាតុចូល, ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្រោចស្រព, ការអនុវត្តវិធានការចម្រុះគ្រប់គ្រងដីជាតិដី តាមរយៈការអនុវត្ត **កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី**, ការផ្តល់សេវាបច្ចេកទេសកសិកម្មល្អប្រសើរ, ការសម្របសម្រួលតភ្ជាប់កសិករ និង ក្រុមផលិត ទៅកាន់ទីផ្សារ និង ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ឱ្យមានលក្ខណៈជាអាជីព ។ ទន្ទឹមនេះ, ត្រូវពង្រឹងការអនុវត្តវិធានការការពារដំណាំ និង ជំរុញការអនុវត្ត **ច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ** ព្រមទាំងទប់ទប់ស្កាត់ការឆ្លងរាលដាលសមាសជាតុចង្រៃ ។

**ទី៦.**ពង្រឹង និង ពង្រីកសហគមន៍ព្រៃឈើ តាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម និង ការគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃ ប្រកបដោយនិរន្តរភាព, ការស្តារព្រៃឈើឡើងវិញ និង ការបន្តអនុវត្តវិធានការចាំបាច់នានា ដើម្បីជួយបង្កើនប្រាក់ចំណូល, លើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ និង រក្សាចីរភាពប្រព័ន្ធអេកូឡូស៊ី ។ ជាមួយគ្នានេះដែរ, ត្រូវបន្តទប់ស្កាត់ និង បង្ក្រាបបទល្មើសនេសាទ និង ការកាប់រាន ដុតឈូសឆាយដីព្រៃលិចទឹកតាមគ្រប់រូបភាព ព្រមទាំងចាត់ការតាមនីតិវិធីឱ្យមានប្រសិទ្ធភាពខ្ពស់ និង ស្មារតីទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ទី៧.**លើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជន ក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម ដើម្បីចូលរួមអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា, ទាំងមុន និង ក្រោយពេលប្រមូលផល, សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទីផ្សារសម្រាប់កសិករ, បង្កើនការអនុវត្ត **ផលិតកម្មកសិកម្មតាមកិច្ចសន្យា** ឱ្យកាន់តែទូលំទូលាយ, និង ជំរុញការកែច្នៃ និង ការនាំចេញនូវផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្មនានា ។

**ទី៨.**លើកកម្ពស់ការសម្របសម្រួល, កិច្ចសហការ និង កិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ក្នុងការជំរុញអនុវត្ត ប្រកបដោយប្រសិទ្ធភាព នូវគោលនយោបាយ, យុទ្ធសាស្ត្រ, កម្មវិធី, វិធានការ និង គម្រោងនានា សំដៅបន្តលើកស្ទួយការអភិវឌ្ឍវិស័យកសិកម្មជាតិ ។

**ទី៩.**ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ, ទាំងក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី, ដើម្បីកៀរគរជំនួយហិរញ្ញវត្ថុ និង ជំនួយបច្ចេកទេសថ្មីៗ សំដៅបន្តការធ្វើទំនើបភាវូបនីយកម្មកសិកម្ម និងបើកទីផ្សារសម្រាប់ផលិតផលកសិកម្មឱ្យបានកាន់ទូលំទូលាយ ។

**ទី១០.**លើកកម្ពស់ប្រសិទ្ធភាពការងារ, សាមគ្គីភាព និង ឯកភាពផ្ទៃក្នុង តាមរយៈការពង្រឹងមុខងារ, ភារកិច្ច និង រចនាសម្ព័ន្ធគ្រប់គ្រង, ការពង្រឹងភាពជាអ្នកដឹកនាំ និង ស្មារតីម្ចាស់ការ ប្រកបដោយការទទួលខុសត្រូវខ្ពស់, ការរៀបចំ និង អនុវត្តឱ្យបានម៉ត់ចត់ នូវក្រមប្រតិបត្តិសម្រាប់បំពេញការងាររបស់មន្ត្រីគ្រប់លំដាប់ថ្នាក់, ការពង្រឹងសមត្ថភាពធនធានមនុស្ស និង ការប្រើប្រាស់គុណាធិបតេយ្យក្នុងការជ្រើសរើស និង តែងតាំងមន្ត្រី ។

**ទី១១.**ចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ, ប្រើប្រាស់ថវិកាជាតិឱ្យចំគោលដៅ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ពង្រឹងការរក្សាការពារ និង ចាត់ចែងទ្រព្យសម្បត្តិរដ្ឋឱ្យបានល្អប្រសើរ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ជាការពិត, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅមានការងារអាទិភាពជាច្រើនទៀតដែលត្រូវបន្តអនុវត្ត ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យកាន់តែរីកចម្រើន ។ ក្នុងស្មារតីនេះ, ខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏សកម្ម និង ប្រកបដោយថាមពលរបស់ **ឯកឧត្តម ឌិត ទីណា** និង ជាពិសេស ដោយមានការគាំទ្រ និង កិច្ចប្រឹងប្រែងរួមរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ-និយោជិតគ្រប់លំដាប់ថ្នាក់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងបន្តសម្រេចបាននូវសមិទ្ធផលជាច្រើនថែមទៀត ជូនជាតិមាតុភូមិ ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធិពរដល់**ឯកឧត្តមរដ្ឋមន្ត្រី, ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី**, ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ៖ **អាយុ, វណ្ណៈ, សុខៈ, និង ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**